**Cambodian - Chicken Pox**

ជម្ងឺឆ្លង - វ៉ាយរីស



# ជម្ងឺអុតស្វាយ

## ចំណុចសំខាន់ៗ

- ជម្ងឺអុតស្វាយគឺជាមេរោគវ៉ាយរីស មានគ្រុន និងស្នាមអុជៗស្បែក
- ស្នាមអុជៗស្បែក ច្រើនឃើញកើតមាននៅផ្នែកកណ្ដាលខ្លួនប្រាណ ក្បាល និងក។
- កុមារអាចចម្លងជម្ងឺនេះអស់រយៈពេលប្រហែលជា៧ថ្ងៃ គឺ២ថ្ងៃមុន រហូតទល់៥ថ្ងៃបន្ទាប់ពីកន្ទួលលេចឲ្យឃើញដំបូង
- ត្រូវដាក់កុមារឲ្យនៅឆ្ងាយពីសាលារៀន មត្តេយ្យសាលា ឬកន្លែងមើលកូនក្មេង រហូតទាល់តែគ្រប់ទាំងស្នាមអុជៗស្បែកបានក្រៀមអស់
- ក្រមរក្រៀមមិនបណ្ដាលឲ្យឆ្លងទេ
- ការព្យាបាលនឹងត្រូវប្រើដើម្បីជួយកុំឲ្យកើតមានអាការៈរោគ ឬដើម្បីការពារមេរោគបាក់តេរីបន្ទាប់បន្សំនៅកន្លែងអុជៗ។

## តើវាជាអ្វី?

ជម្ងឺអុតស្វាយគឺជាជម្ងឺទូទៅដែលបណ្ដាយមកពីវ៉ាយរីស (varicella - zoster)។ កូនក្មេងប្រហែលជាមិនស្រួលខ្លួនអស់រយៈពេលមួយថ្ងៃ ឬពីរថ្ងៃដោយមានគ្រុន បន្ទាប់មកកើតមានពណ៌ក្រហមនៅស្បែក ហើយក្រោយៗមកកើតមានការរាលដាលពាសពេញនៃក្រុមពកក្រហមតូចៗ (ដែលមានស្បែកពណ៌ស្វាយ ឬពណ៌ត្នោត) ដែលក្នុងរយៈពេល២-៤ថ្ងៃខាងមុខក៏កើតទៅជាពងបែក។ ពងបែកក៏ក្លាយទៅជាពណ៌ស ដែលមានខ្ទុះអស់រយៈពេល២ ឬ៣ថ្ងៃ រួចមកក៏ក្រៀមទៅជាក្រមរពណ៌ខ្មៅ។

ស្នាមអុជៗជាទូទៅច្រើនកើតមាននៅផ្នែកកណ្ដាលដងខ្លួន ក្បាល និងក ហើយមិនសូវកើតមាននៅលើដៃ និងជើងទេ។ ចំនួននៃស្នាមអុជៗអាចប្រែប្រួល។

កូនក្មេងដែលមានអាយុ២-១០ឆ្នាំ ជាទូទៅច្រើនតែត្រូវបានប៉ះពាល់ដោយជម្ងឺអុតស្វាយ។ គ្រុន និងកន្ទួលលេចឲ្យឃើញប្រហែលជា២អាទិត្យក្រោយពីបានប៉ះពាល់ជាមួយអ្នកជម្ងឺ។ ជម្ងឺអុតស្វាយអាចឆ្លងចាប់ពី២ថ្ងៃមុនកន្ទួលលេចឲ្យឃើញ រហូតដល់៥ថ្ងៃបន្ទាប់ពីវាបង្ហាញឲ្យឃើញដំបូង។ ក្រមរក្រៀមមិនបណ្ដាលឲ្យឆ្លងទេ។ បន្ទាប់ពីម្នាក់បានកើតជម្ងឺអុតស្វាយមក នោះក៏កើតមានភាពស៊ាំនឹងជម្ងឺអស់រយៈពេលដ៏យូរលង់ ហើយការកើតជាលើកទីពីរគឺកម្រមានណាស់។

## តើគេការពារវាដោយរបៀបណា?

ដើម្បីការពារកុំឲ្យឆ្លងដល់អ្នកដទៃ កូនក្មេងត្រូវតែរក្សាទុកនៅឲ្យនៅឆ្ងាយពីសាលារៀន មត្តេយ្យសាលា ឬកន្លែងមើលកូនក្មេងរហូតទាល់តែស្នាមអុជៗស្បែកបានក្រៀមអស់។ ថ្វីដ្បិតតែនេះមិនមែនជាផ្នែកនៃកម្មវិធីចាក់ថ្នាំការពារជាលំដាប់ក្តី គឺមានថ្នាំសំរាប់ចាក់ការពារជម្ងឺអុតស្វាយ។ ថ្នាំចាក់ការពារទាំងនេះសំរាប់ចាក់មួយដងឲ្យកូនក្មេងដែលមានអាយុលើសពី១២ខែ។

## តើគេព្យាបាលវារបៀបណា?

កូនក្មេងភាគច្រើនដែលកើតជម្ងឺអុតស្វាយ មិនចាំបាច់ត្រូវការការព្យាបាលប្រឆាំងមេរោគវ៉ាយរីសពិសេសណាមួយឡើយ។ ការព្យាបាលគឺប្រើដើម្បីទប់ទល់នឹងគ្រុន និងដើម្បីការពារមេរោគបាក់តេរីបន្ទាប់បន្សំនៃស្នាមអុជៗស្បែក។ ប្រសិនបើមេរោគបាក់តេរីកើតមានឡើង នោះវាអាចនាំឲ្យកើតមានស្លាកស្នាម។ ប្រេងសំរាប់ងូតក្នុងអាងទឹកដែលប្រឆាំងទប់ទល់នឹងបាក់តេរី និងរមាស់អាចជួយ។ ថ្នាំសម្លាប់មេរោគអាចប្រើលើស្នាមអុជៗស្បែក ដើម្បីការពារមេរោគបាក់តេរីបន្ទាប់បន្សំ។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក

© 2002, Department of Dermatology, St. Vincent's Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.